**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម ។
កណ្ដាល. ថ្ងៃទី១៩ ខែ 6 ឆ្នាំ ២០14
ក្រឡាបញ្ជី
ញ៉ាំ.ចាន់ចាំ

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ៖៥២០ អ.ក
ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១២
សាលក្រមលេខ៖ ១៥ (ឆ.ព.ន)
ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅសាលាដំបូងខេត្តកណ្ដាលនាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង ៩ ព្រឹកដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះ លើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៥២០ អក ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១២ ដែលមានជនជាប់ចោទ៖

១/ ឈ្មោះ[redacted]ភេទប្រុស អាយុ២៥ ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើត នៅភូមិព្រៃកតាដុល ឃុំពោធិ៍បាន ស្រុកកោះធំ ខេត្តកណ្ដាល និង ទីលំនៅបច្ចុប្បន្ន នៅភូមិព្រៃកតាដុល ឃុំពោធិ៍បាន ស្រុកកោះធំ ខេត្តកណ្ដាល ឪពុកឈ្មោះ[redacted] (រស់) ម្ដាយឈ្មោះ[redacted](ស្លាប់) ប្រពន្ធឈ្មោះ [redacted] (រស់) មានកូន០២ នាក់ ។

ជាប់ចោទពីបទ៖ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិទួលក្រសាំង ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

**ដំណើររឿងហេតុមានដូចតទៅ**

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ វេលាម៉ោង០១ និងសូន្យនាទី ស្ថិតនៅភូមិទួលក្រសាំង ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល មានឈ្មោះ [redacted]បានជិះម៉ូតូជាមួយនឹងឈ្មោះ[redacted] ទៅធ្វើសកម្មភាពលួចយកម៉ូតូ ដោយឈ្មោះ [redacted] ជាអ្នកចាំទទួលនៅរង្វង់មូលតាខ្មៅហើយឈ្មោះ [redacted] ជាអ្នកទៅយកម៉ូតូម៉ាក ហុង ដា សេ ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ ១AP-១២៧៨ ជាកម្មសិទ្ធិរបស់ឈ្មោះ[redacted]ហើយពេលឈ្មោះ[redacted]លួចបានសម្រេច ក៏បានយក



Scanned by CamScanner

មកលក់ឲ្យទៅឈ្មោះ[redacted] ក្នុងតំលៃ៣៣០$ ដោយគ្មានលិខិតស្នាមអ្វីឡើយ។ លុះដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ ក៏ត្រូវបានម្ចាស់ម៉ូតូឃើញ និងរាយការណ៍ជូនប៉ូលីសចាប់បានតែម្តង។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ២៩៥ ដកសព ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

បានឃើញ ដីកាដំណោះស្រាយលេខ៖ ១៩៨ ដកដស ចុះថ្ងៃទី២៣ ខែ មេសា ឆ្នាំ២០១៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

បានឃើញ ចំណារចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា៖ ខ្លួនសូមទទួលស្គាល់ចម្លើយរបស់ខ្លួនដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តធម៌, តំណាងអយ្យការ និងចៅក្រមស៊ើបសួរទុកជាបានការដដែរ។ នៅថ្ងៃខែមិនចាំក្នុងឆ្នាំ ២០១២ ខ្លួនបានទិញម៉ូតូម៉ាក ហុងដាសេ ១២៥ ស៊េរីឆ្នាំ ២០១០ ពីឈ្មោះ ខន ក្នុងតម្លៃ ៣៣០ ដុល្លាអាមេរិក ដោយខ្លួនមិនមានលិខិតស្នាមអ្វីទេ នៅវង្វង់មូលតាខ្មៅ។ បន្ទាប់មករូបខ្លួនក៏បានជិះម៉ូតូនោះមកផ្ទះនៅស្រុកកោះធំ។ លុះដល់ថ្ងៃទី១០ ខែ កក្កដា ឆ្នាំ២០១២ វេលាម៉ោង ៨ ព្រឹក ពេលរូបខ្លួនជិះម៉ូតូទៅធ្វើការនៅកន្លែងលក់អេតចាយ ស្ថិតនៅគីឡូលេខ៦ ភ្នំពេញ ស្រាប់តែកូនប្រុសរបស់អ៊ំប្រុសម្ចាស់ម៉ូតូឃើញ ក៏ចាប់ឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។ ខ្លួនស្នើសុំដល់តុលាការជួយបន្ធូរបន្ថយទោស។

-អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted]បានឆ្លើយថា៖ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១២ វេលាម៉ោង ៦ ល្ងាច រូបខ្លួនអូសម៉ូតូយកទៅទុកនៅផ្ទះ ដោយបានចាក់សោរទ្វារមុខ រួចបានចូលដេក ហើយលុះដល់ថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០១២ វេលាម៉ោងប្រហែល ៤ និង ២០នាទីទៀបភ្លឺ កូនប្រុសរបស់ខ្លួនឈ្មោះ [redacted] បានមកសួររូបខ្លួនថា ម៉ែម៉ូតូទុកនៅឯណា? រូបខ្លួនបានប្រាប់ថា ម៉ូតូទុកនៅខាងមុខ ពេលនោះកូនប្រាប់ថា អត់ឃើញម៉ូតូទេ ភ្លាមនោះរូបខ្លួនក៏បានងើបមកមើលម៉ូតូ ស្រាប់តែមិនឃើញម៉ូតូទេ ឃើញតែសោរទ្វារនៅលើតុ បន្ទាប់មករូបខ្លួនក៏បានដាក់ពាក្យបណ្តឹង នៅប៉ុស្តិ៍រដ្ឋបាលនគរបាលរការខ្ពស់ ។ លុះដល់ថ្ងៃទី១០ខែ កក្កដា ឆ្នាំ២០១២ វេលាម៉ោង១០ និង៣០នាទីព្រឹក កូនប្រុសរបស់ខ្លួនឈ្មោះ [redacted] បានទូរស័ព្ទប្រាប់ថា ម៉ែអើយចាប់បានអ្នកលួចម៉ូតូយើងហើយនៅម្តុំគីឡូម៉ែត្រលេខ ៦ រាជធានីភ្នំពេញ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយថា៖ កាលពីថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ ២០១២ វេលាម៉ោងប្រហែល ៤ និង២០នាទីទៀបភ្លឺ រូបខ្លួនបានភ្ញាក់ពីដេក ដើរទៅរកយកម៉ូតូរបស់ខ្លួន ម៉ាកហុងដាឌ្រីមដេ ១២៥ ស៊េរី២០១០ ពណ៌ខ្មៅ នៅក្នុងបន្ទប់ដាក់ម៉ូតូ ស្រាប់តែបាត់ម៉ូតូ ហើយលុះដល់ថ្ងៃទី១០ ខែ កក្កដា ឆ្នាំ២០១២ វេលាម៉ោងប្រហែល ៨ និង៥០នាទីព្រឹក ពេលរូបខ្លួនកំពុងដើរចេញពីកន្លែងទិញអេតចាយ នៅគីឡូម៉ែត្រលេខ៦ ភ្នំពេញ ស្រាប់តែឃើញ ជនត្រូវចោទឈ្មោះ សែម [redacted] កំពុងជិះម៉ូតូរបស់ខ្លួននៅតាមផ្លូវ ភ្លាមនោះរូបខ្លួនក៏ចាប់ឃាត់ខ្លួនជនត្រូវចោទប្រគល់ឲ្យនគរបាលប៉ុស្តិ៍គីឡូម៉ែត្រលេខ ៦ តែម្តង។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: តាមចម្លើយជនជាប់ចោទ, អំណានចម្លើយជនរងគ្រោះ និងអំណានចម្លើយសាក្សី អាចបញ្ជាក់បានថា កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ ជនជាប់



Scanned by CamScanner

ចោទពិតជាបានទិញម៉ូតូដែលឈ្មោះ [redacted] បានលួចពីជនរងគ្រោះក្នុងតម្លៃ ៣៣០ ដុល្លា ហើយជនជាប់ចោទក៏បានដឹងថា ម៉ូតូនោះជាម៉ូតូដែលឈ្មោះ [redacted]បានលួចពីគេដែរ។ ហេតុដូច្នេះតំណាងអយ្យការយល់ឃើញថា មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ[redacted]ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរពីបទ៖ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិទួលក្រសាំង ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា៤០០ នៃក្រមពហ្មទណ្ឌ និងស្នើសុំដល់តុលាការសម្រេចផ្តន្ទាទោសជនល្មើសតាមច្បាប់។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

## សាលាដំបូងខេត្តកណ្តាល

## យល់ឃើញថា

១.ជនជាប់ចោទឈ្មោះ[redacted] បានឆ្លើយថា៖ ខ្លួនពិតជាបានទិញម៉ូតូម៉ាក ហុងដាសេ ១២៥ ស៊េរីឆ្នាំ ២០១០ ពីឈ្មោះ ខន ក្នុងតម្លៃ ៣៣០ ដុល្លាអាមេរិក ដោយខ្លួនមិនមានលិខិតស្នាមអ្វីទេ នៅវង្វង់មូលតាខ្មៅប្រាកដមែន។

២.តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted]និងសាក្សីឈ្មោះ [redacted] បានឆ្លើយស៊ីសង្វាក់គ្នាថា៖ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១២ ឈ្មោះ[redacted] បានទុកម៉ូតូនៅក្នុងផ្ទះ លុះវេលាម៉ោងប្រហែល ៤ទៀបភ្លឺថ្ងៃខែឆ្នាំដដែរ ឈ្មោះ [redacted]ក់ឡើងមិនឃើញម៉ូតូ ក៏បានទៅប្តឹងសមត្ថកិច្ច។ លុះដល់ថ្ងៃទី១០ ខែ កក្កដា ឆ្នាំ២០១២ វេលាម៉ោងប្រហែល ៨ និង៥០នាទីព្រឹក ពេលឈ្មោះ [redacted] កំពុងដើរចេញពីកន្លែងទិញអេតចាយ នៅគីឡូម៉ែត្រលេខ៦ ភ្នំពេញ ស្រាប់តែឃើញ ជនត្រូវចោទឈ្មោះ សែម ពិសិដ្ឋ កំពុងជិះម៉ូតូរបស់ខ្លួននៅតាមផ្លូវ ភ្លាមនោះរូបខ្លួនក៏ចាប់ឃាត់ខ្លួនជនត្រូវចោទ ប្រគល់ឲ្យនគរបាលប៉ុស្តិ៍គីឡូម៉ែត្រលេខ៦ តែម្តង។

៣.តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ ជនជាប់ចោទពិតជាបានទិញម៉ូតូដែលឈ្មោះ[redacted]បានលួចពីជនរងគ្រោះក្នុងតម្លៃ ៣៣០ ដុល្លា ហើយជនជាប់ចោទ ក៏បានដឹងថាម៉ូតូនោះ ជាម៉ូតូដែលឈ្មោះ[redacted]បានលួចពីគេដែរ។ ហេតុដូច្នេះតំណាងអយ្យការយល់ឃើញថា មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted]ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរពីបទ៖ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិទួលក្រសាំង ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា៤០០ នៃក្រមពហ្មទណ្ឌ និងស្នើសុំដល់តុលាការសម្រេចផ្តន្ទាទោសជនល្មើសតាមច្បាប់។

៤.តាមចម្លើយជនជាប់ចោទ ជនរងគ្រោះ និងសាក្សី អាចបញ្ជាក់បានថា កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ ជនជាប់ចោទឈ្មោះ[redacted]ពិតជាមានចេតនាទិញម៉ូតូពីឈ្មោះ[redacted]ដល



Scanned by CamScanner

បានលួចពីជនរងគ្រោះឈ្មោះ [redacted] ដោយខ្លួនពិតជាបានដឹងច្បាស់ថា ម៉ូតូនោះ ជាផលនៃអំពើចោរកម្មប្រាកដមែន ដែលអំពើនេះច្បាប់ចាត់ទុកថាជាបទៈ ទទួលផលចោរកម្ម បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០០ នៃក្រមពហ្មទណ្ឌ។

៥.អំពើរបស់ជនត្រូវចោទឈ្មោះ [redacted] បានធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម និងទ្រព្យសម្បត្តិរបស់បុគ្គលឯកជន ហើយជនត្រូវចោទជានីតិជន មានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយពុំមានសញ្ញាណាមួយបញ្ជាក់ថាជនជាប់ចោទមានបញ្ហាខាងសតិស្មារតីឡើយ។

៦.មានភស្តុតាង និងធាតុផ្សំដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ទប្រុស អាយុ២៥ ឆ្នាំ ជាតិខ្មែរពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិទួលក្រសាំង ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

**ហេតុដូច្នេះសម្រេចសេចក្តី**

ផ្តន្ទាទោសៈ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ២ ឆ្នាំ ៦ ខែ (ពីរឆ្នាំប្រាំមួយខែ) ពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិទួលក្រសាំង ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០០ នៃក្រមពហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជម្រះ**

[redacted]

បានឃើញ
ថ្ងៃ ទី 24 ខែ មិថុនា ឆ្នាំ 2013
តំណាងអយ្យការ

[redacted]



Scanned by CamScanner